Washington State
Department of Social & Health Services

# ជម្រើសរបស់អ្នកសម្រាប់ការទារប្រាក់ឧបត្ថម្ភកូន ក្នុងខណៈកំពុងទទួល ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារក្រខ្សត់ (TANF) ឬជំនួយវេជ្ជសាស្ត្រ

# Your Options for Child Support Collection while Receiving Temporary Assistance for Needy Families (TANF)

លើកលែងតែវាគ្មានសុវត្ថិភាពសម្រាប់រូបអ្នក ឬកូនៗរបស់អ្នក, ច្បាប់តម្រូវឲ្យអ្នកត្រូវតែជួយក្រសួងសេវាសង្គមកិច្ចនិងសុខាភិបាល (Department of Social and Health Service, DSHS), នាយកដ្ឋានឧបត្ថម្ភកុមារ (Division of Child Support, DCS), ទារប្រាក់ឧបត្ថម្ភឧបកូន និង/ឬប្រាក់ឧបត្ថម្ភ វេជ្ជសាស្ត្រ នៅពេលណាអ្នកទទួលជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារក្រខ្សត់ (Temporary Assistance for Needy Families, TANF) ឬជំនួយ វេជ្ជសាស្ត្រសម្រាប់រូបអ្នក ឬកូនៗរបស់អ្នក។ DCS ផ្តល់សេវាបង្កើតអោយមានការឧបត្ថមកុមារនៅពេលដែលអ្នកទទួលបាន TANF។ សេវាទាំងនេះមានរួម ការបង្កើតអោយមានដីការរបស់ DCS ទៅកាន់អាណាព្យាបាលម្ខាង ទៀតនូវកាតព្វកិច្ចផ្តល់ការធានារ៉ាប់រងសុខភាព និង បរិច្ចាកចំណែកនៃការចំណាយវិជ្ជសាស្ត្រដែលមិនស្ថិតនៅក្នុងការធានាសំរាប់កូនៗរបស់អ្នក។

**តើខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីជួយ DCS ទារប្រាក់ឧបត្ថម្ភកូន ?**

- ប្រាប់ឈ្មោះឪពុកឬម្តាយម្ខាងទៀត ឬឪពុកម្តាយទាំងពីររបស់កូន(ៗ)រូបនេះ។
- ផ្តល់ព័ត៌មានមកយើង ដើម្បីតាមរកឪពុកឬម្តាយម្ខាងទៀត ឬឪពុកម្តាយទាំងពីរ។
- ជួយផ្តល់ភ័ស្តុតាងបញ្ជាក់មុខឪពុកឬម្តាយម្ខាងទៀត ឬឪពុកម្តាយទាំងពីររបស់កូន(ៗ)រូបនេះ។

**ហេតុអ្វីបានជាវាមានសារប្រយោជន៍ក្នុងការបង្កើតបិតុភាព និងទារប្រាក់ឧបត្ថម្ភកូន ?**

- ពីព្រោះប្រាក់ឧបត្ថម្ភកូន អាចជួយអ្នកឲ្យសម្រេចបានភាពការលើខ្លួនឯង។
- ពីព្រោះវាធ្វើឲ្យកូន(ៗ)របស់អ្នកមានប្រវត្តិគ្រួសារជាក់លាក់មួយ ដោយដឹងថា នរណាជាឪពុកម្តាយរបស់(ពួក)គេ។
- ពីព្រោះវាធ្វើឲ្យកូន(ៗ)របស់អ្នកមានសិទ្ធិពេញច្បាប់ក្នុងការទទួលមរតក, ជំនួយសន្តិសុខសង្គម, កម្រៃអតីតយុទ្ធជន, និងកម្រៃរ៉ាប់រងដទៃៗ ទៀតរបស់រដ្ឋាភិបាល។

**ចុះបើខ្ញុំមិនធ្វើសហការជាមួយ DCS?**

បើអ្នកមិនជួយ DCS ទារប្រាក់ឧបត្ថម្ភកូន ហើយអ្នកមិនត្រូវបានអនុម័តថា មាន "មូលហេតុត្រឹមត្រូវ" ("Good Cause") ទេ, នោះជំនួយប្រាក់សុទ្ធរបស់អ្នកអាចនឹងត្រូវកាត់បន្ថយ 25%។

**តើនៅពេលណាទើបវាមានលក្ខណៈសមរម្យក្នុងការ *មិន* ធ្វើសហការជាមួយ DCS?**

អ្នកមិនចាំបាច់ជួយទារប្រាក់ឧបត្ថម្ភកូនទេ ប្រសិនបើការិយាល័យសេវាសហគមន៍ (Community Services Office, CSO) របស់អ្នកកំណត់ឃើញថា អ្នកមានមូលហេតុត្រឹមត្រូវក្នុងការមិនជួយ។ មូលហេតុត្រឹមត្រូវរួមមាន ៖

- អ្នកមានការភ័យខ្លាចថា រូបអ្នក ឬកូន(ៗ)របស់អ្នក ដែលមានឈ្មោះក្នុងសំណុំរឿងរបស់អ្នក នឹងទទួលរងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់រាងកាយ ឬ អារម្មណ៍។
- កូនរបស់អ្នកបានកើតមកដោយសាររូបអ្នកត្រូវគេចាប់រំលោភ។
- អ្នកកំពុងចាប់ផ្តើមនីតិវិធីដាក់កូនឲ្យគេចិញ្ចឹម, ឬអ្នកកំពុងប្រឹក្សាយោបល់ (រហូតដល់ចំនួនបីខែ) ជាមួយទីភ្នាក់ងារចិញ្ចឹមកុមារ ដើម្បីស្វែងរកលទ្ធភាពដាក់កូនឲ្យគេចិញ្ចឹម។

**តើខ្ញុំត្រូវផ្តល់ភ័ស្តុតាងអ្វីខ្លះទៅបុគ្គលិកធ្វើការ CSO របស់ខ្ញុំ ដើម្បីបង្ហាញថា ខ្ញុំមានមូលហេតុត្រឹមត្រូវក្នុងការមិនជួយពួកគេ?**

- សេចក្តីថ្លែងការណ៍ដែលអ្នកបានចុះហត្ថលេខា ដើម្បីផ្តល់មូលហេតុស្តីពីការភ័យខ្លាច ឬការបារម្ភផ្សេងៗរបស់អ្នក។
- ឯកសារណាមួយដែលរួមមានដូចជា ឯកសារវេជ្ជសាស្ត្រ, ឯកសារប៉ូលិស, ឬឯកសារណាៗទៀតស្តីពីការបារម្ភអំពីសុវត្ថិភាពរបស់អ្នក, ប្រសិនបើមាន។

**តើខ្ញុំនៅតែអាចឲ្យគេទារប្រាក់ឧបត្ថម្ភកូន ពីឪពុកឬម្តាយម្ខាងទៀត ដោយមិនចាំបាច់ធ្វើសហការជាមួយ DCS បានទេ?**

បាន ពីព្រោះមានវិធានការពីកម្រិតខុសៗគ្នា ដែលអ្នកអាចជ្រើសរើស; កម្រិត Level A ឬកម្រិត Level B ។

- Level A ៖ គេនឹង *មិន* ស្នើសុំឲ្យអ្នកធ្វើសហការជាមួយ DCS ទេ។ គេក៏នឹងមិនទារប្រាក់ឧបត្ថម្ភកូន ។
- Level B ៖ គេនឹងមិនស្នើសុំអោយអ្នកធ្វើសហការជាមួយ DCS ទេ ប៉ុន្តែគេនឹងទារប្រាក់ឧបត្ថមកូន និង អាស័យដ្ឋាននឹងរក្សាដោយការសំងាត់ និង អាស័យដ្ឋានរបស់អ្នកត្រូវបានការពារដោយសំងាត់។

**តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើវាលែងមានសុវត្ថិភាពសម្រាប់ឲ្យ DCS បន្តទារប្រាក់ឧបត្ថម្ភកូន តទៅទៀតនោះ?**

- ចូរទាក់ទងបុគ្គលិកធ្វើការ CSO របស់អ្នក និងមន្ត្រីឧបត្ថម្ភកុមារ DCS របស់អ្នកជាបន្ទាន់។ ប្រាប់មន្ត្រីទាំងពីររូបអំពីស្ថានភាពថ្មីរបស់អ្នក។
- ចូរស្នើសុំការអនុគ្រោះដោយយោងលើមូលហេតុត្រឹមត្រូវ តាមរយៈការបំពេញទម្រង់នេះ។
- ប្រសិនបើបច្ចុប្បន្ននេះអ្នកមានមូលហេតុត្រឹមត្រូវ Level B, នោះចូរពិចារណាអំពីការសុំប្តូរទៅ Level A។
- ចូរស្នើសុំឲ្យគេបញ្ជូនអ្នកទៅជួបអង្គភាពគាំពារពីអំពើហិង្សាក្នុងគ្រួសារប្រចាំការិយាល័យ ឬប្រចាំហគមន៍មូលដ្ឋានរបស់អ្នក។

**ចុះបើខ្ញុំមិនយល់ស្របជាមួយនឹងសេចក្តីសម្រេចយោងតាមមូលហេតុត្រឹមត្រូវរបស់ CSO?**

អ្នកមានសិទ្ធិស្នើសុំសវនាការរដ្ឋបាល (Administrative Hearing) ដើម្បីពិនិត្យសើរើសម្រេចយោងតាមមូលហេតុត្រឹមត្រូវនោះបាន។ សវនាការរដ្ឋបាល គឺជានីតិវិធីពិនិត្យសើរើសេចក្តីសម្រេចយោងតាមមូលហេតុត្រឹមត្រូវ។ សូមមើល "នីតិវិធីសវនាការរដ្ឋបាល" ("Administrative Hearing Process") នៅលើទំព័រទ្ធាប់ ដើម្បីស្វែងយល់ព័ត៌មានពិស្តារបន្ថែមស្តីពីសវនាការរដ្ឋបាល។

បើអ្នកមានសំណួរអ្វីមួយស្តីពីការជួយទារប្រាក់ឧបត្ថម្ភកូន , ចូរសួរគេឲ្យច្បាស់លាស់ជាមុនសិន មុននឹងចុះហត្ថលេខាលើទម្រង់ នេះ។ ពីក្នុងចំណោមសេចក្តីថ្លែងការណ៍ទាំងប៉ុន្មានខាងក្រោមនេះ, ចូរគូសតែសេចក្តីថ្លែងការណ៍មួយដែលអនុវត្តចំពោះរូបអ្នកប៉ុណ្ណោះ។

☐ ខ្ញុំជឿថា វាមានសុវត្ថិភាពសម្រាប់ខ្ញុំនិងកូន(ៗ)របស់ខ្ញុំ សម្រាប់ឲ្យ DCS ទារប្រាក់ឧបត្ថម្ភកូន ។ ខ្ញុំយល់ថា ខ្ញុំត្រូវតែជួយ DCS ទារប្រាក់ឧបត្ថម្ភកូន ហើយបើខ្ញុំមិនជួយទេ, នោះជំនួយប្រាក់សុទ្ធរបស់ខ្ញុំនឹងត្រូវកាត់បន្ថយ 25%។

☐ ខ្ញុំមានមូលហេតុត្រឹមត្រូវក្នុងការមិនជួយ។ សូមពណ៌នាមូលហេតុរបស់អ្នក ដោយពន្យល់អំពីការភ័យខ្លាច និងការបារម្ភរបស់អ្នកនៅលើទំព័របន្ទាប់។

| |
|---|
| សូមពណ៌នាមូលហេតុរបស់អ្នកសម្រាប់ការស្នើសុំមូលហេតុត្រឹមត្រូវ ដោយពន្យល់រៀបរាប់អំពីការភ័យខ្លាច និងការបារម្ភនានារបស់អ្នក។ |

| | |
|---|---|
| **ខ្ញុំសូមស្បថថា សេចក្តីថ្លែងការណ៍ទាំងប៉ុន្មានដែលខ្ញុំបានផ្តល់ជូនខាងលើសុទ្ធតែត្រឹមត្រូវពិតប្រាកដ។** | |
| ឈ្មោះរបស់អតិថិជន (សូមសរសេរឲ្យច្បាស់។) | លេខ ID របស់អតិថិជន |
| ហត្ថលេខារបស់អតិថិជន | កាលបរិច្ឆេទ |
| **ខ្ញុំបានប្រគល់សំណៅចម្លងនៃទម្រង់នេះទៅឲ្យអតិថិជនរួចរាល់ហើយ។** | |
| ហត្ថលេខារបស់បុគ្គលិកធ្វើការ | កាលបរិច្ឆេទ |
| ឈ្មោះរបស់ឪពុកឬម្តាយមិនមែនជាអ្នកអាណាព្យាបាលកូន | លេខ ID របស់អតិថិជន |
| ឈ្មោះរបស់កូន | លេខ ID របស់អតិថិជន |
| ឈ្មោះរបស់កូន | លេខ ID របស់អតិថិជន |
| ឈ្មោះរបស់កូន | លេខ ID របស់អតិថិជន |

## នីតិវិធីសវនាការរដ្ឋបាល

1. អ្នកអាចទូរស័ព្ទទាក់ទងទៅការិយាល័យសេវាសហគមន៍ (CSO) ប្រចាំមូលដ្ឋានរបស់អ្នក ដើម្បីស្នើសុំឲ្យគេពិនិត្យសើរើសំណុំរឿងរបស់អ្នកបាន។
2. អ្នកអាចទូរស័ព្ទទាក់ទងទៅ CSO របស់អ្នក ឬសរសេរលិខិតលាយលក្ខណ៍អក្សរទៅ The Office of Administrative Hearings, PO Box 42489, Olympia, WA 98504-2489 ឲ្យទាន់ក្នុងរយៈពេល 90 ថ្ងៃ ដើម្បីស្នើសុំសវនាការ។ បើអ្នកស្នើសុំសវនាការ, នោះ DCS នឹងមិនចាប់ផ្តើមធ្វើការលើសំណុំរឿងរបស់ទេ រហូតទាល់តែសេចក្តីសម្រេចនៃអង្គសវនាការបានបញ្ចប់ជាស្ថាពរ។

   មេធាវីឬជនណាម្នាក់ ដែលអ្នកបានជ្រើសរើស អាចតំណាងឲ្យរូបអ្នកនៅក្នុងអង្គសវនាការ, ឬអ្នកអាចតំណាងឲ្យខ្លួនឯកក៏បាន។

### តើខ្ញុំអាចទទួលបានការប្រឹក្សាយោបល់ផ្នែកច្បាប់ ឬការតំណាងដោយអ្នកច្បាប់ឬទេ?

អ្នកអាចអញ្ជើញសាកល្បងទូរស័ព្ទទាក់ទងទៅបណ្តាញសេវាច្បាប់ទូទាំងរដ្ឋ តាមលេខ 1-888-201-1014 ។